# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:...០១...សរណន**

០៤៤
11.7.13 16.0

# គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល
# ស្តីពី
# ការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរពលករទេសន្តរប្រវេសន៍កម្ពុជា

ដោយមើលឃើញថា៖ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនយើងបាននាំគ្នាធ្វើចំណាកស្រុកនិងឆ្លងដែនទៅធ្វើការនៅប្រទេសក្រៅយ៉ាងគគ្រឹកគគ្រេង មានទាំងទៅតាមប្រព័ន្ធផ្លូវការ និងទាំងតាមប្រព័ន្ធមិនផ្លូវការដោយអាណាធិបតេយ្យ និងពុំមានការគ្រប់គ្រងច្បាស់លាស់ ។

នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.អ) កាលពីថ្ងៃទី ២៦ ដល់ទី២៨ ខែមិនា ឆ្នាំ២០១៣ នៅក្រសួងមហាផ្ទៃ យើងបានឯកភាពគ្នាហើយថា៖ ចំណាកស្រុក ឬទេសន្តរប្រវេសន៍ គឺជាចរន្តធម្មជាតិរបស់មនុស្សដែលព្យាយាមត្រាច់ចរ ដើម្បីស្វែងរកភាពរីកចម្រើនក្នុងជីវិតរស់នៅ ។ ប៉ុន្តែចំណុចដែលគួរឲ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ននេះ គឺ <u>ភាពរងគ្រោះរបស់ប្រជាពលរដ្ឋក្នុងពេលធ្វើទេសន្តរប្រវេសន៍ និងភាពអាណាធិបតេយ្យនៃការធ្វើចំណាកស្រុក ចាំបាច់ត្រូវគ្រប់គ្រង និងការពារ</u> ។

ចំណាកស្រុក និងបញ្ហាទេសន្តរប្រវេសន៍បានក្លាយជារបៀបវារៈមួយសម្រាប់ការគិតគូរក្នុងក្របខ័ណ្ឌគោលនយោបាយជាតិ និងអន្តរជាតិ ដែលប្រទេសទាំងឡាយលើសកលលោកកំពុងតែប្រឈមនឹងការរកដំណោះស្រាយដែលមានប្រសិទ្ធិភាព ជាពិសេសដើម្បីសម្របសម្រួលឲ្យមានភាពសុខដុម និងកិច្ចសហការល្អរវាងប្រទេសបញ្ជូន និងប្រទេសទទួល ពោលគឺប្រទេសដែលមានកម្លាំងពលកម្ម និងប្រទេសដែលត្រូវការកម្លាំងពលកម្ម ។ កិច្ចការនេះ ត្រូវការភាពឈ្លាសវៃ និងអត់ធ្មត់ក្នុងការដោះស្រាយ ព្រោះថា ជាការប្រកួតប្រជែងផ្នែកនយោបាយសេដ្ឋកិច្ច និងសង្គម ដែលប្រទេសនីមួយៗ ចាំបាច់ត្រូវការពារផលប្រយោជន៍ជាតិ និងប្រជាជនរៀងៗខ្លួន ។ ទន្ទឹមនឹងនោះ ជនល្មើសតែងប្រើប្រាស់ភាពខ្វះចន្លោះនៃកិច្ចសហការ និងការអនុវត្តន៍ច្បាប់ ដើម្បីកេងយកផលចំណេញពីគ្រប់តំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍ ធ្វើឲ្យពលករទទួលរងនូវការខាតបង់ ការឈឺចាប់ និងការលំបាកច្រើនរាប់មិនអស់ ក្នុងនោះ

- ពង្រឹងកិច្ចសហការផ្ទៃក្នុង រវាងក្រសួង ស្ថាប័នពាក់ព័ន្ធឲ្យបានជិតស្និទ្ធ និងជម្រុញឲ្យមានកិច្ចព្រមព្រៀង ឬអនុស្សរណៈ ជាមួយប្រទេស ពាក់ព័ន្ធ ដោយមានខ្លឹមសារគ្រប់គ្រាន់ នីតិវិធីច្បាស់លាស់ប្រកបដោយការទទួលខុសត្រូវ ដើម្បីធានាដល់ការការពារពលករផង និងកិច្ចសហប្រតិបត្តិការល្អផង ជាពិសេសជាមួយស្ថានទូតកម្ពុជានៅក្នុងប្រទេសពាក់ព័ន្ធ ។
- ជម្រុញឲ្យក្រុមការងារទេសន្តរប្រវេសន៍ ដែលមានក្រសួងមហាផ្ទៃ និងក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈជាស្នូល ពិនិត្យលទ្ធភាពក្នុងការកសាងនីតិវិធីសមស្រប និងកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ដើម្បីការពារ និងគ្រប់គ្រងពលករដែលស្វែងរកការងារមិនតាមប្រព័ន្ធរៀបរយដែលមានបច្ចុប្បន្ន និងបង្វែរការផ្តល់ភាពស្របច្បាប់ក្រោយពេលចូលទៅធ្វើការងារដោយខុសច្បាប់ ទៅជាការធានាភាពស្របច្បាប់ តាំងពីមុនពេលឆ្លងដែន។
- ជម្រុញការតាមដានត្រួតពិនិត្យ វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍នេះ និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រីអំពីភាពរីកចំរើន ។

ទទួលបានគោលការណ៍ណែនាំនេះ សូមឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពចាប់ពីពេលនេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៣

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី

-គ្រប់ខុទ្ទកាល័យក្រសួងស្ថាប័ន

-គ្រប់សាលារាជធានីខេត្ត

-ឯកសារ កាលប្បវត្តិ



CS Scanned with CamScanner